# ដំណាំសណ្ដែកគួរ



## ការរៀបចំដី

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ ស.ម យ៉ាងតិចនៅរដូវវស្សា)
- ពង្រាយដីលាមកគោស្ងួតរឺជីកំប៉ុស្ដ៍ និងជីកែង១ពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើងអោយបានកំរាស់យ៉ាងតិច៥សង់ទីម៉ែត្រ រឺប្រើគំរបជីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី



## ការដាំដោយគ្រាប់ផ្ទាល់

- ដាក់២គ្រាប់ក្នុង១រណ្ដៅដែលមានជំរៅ២ស.ម បើកប់គ្រាប់ជ្រៅពេកគ្រាប់សណ្ដែកពិបាកដុះពន្លកចេញពីដី ។បន្ទាប់ពីដាក់គ្រាប់ហើយត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់។ បើទឹកតិចពេក គ្រាប់មិនអាចដុះឬច្រើនពេក ធ្វើអោយគ្រាប់អាចរលួយ ។
- ត្រូវស្រោចទឹកកូនសណ្ដែកឲ្យបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយជាពិសេសរវាងពី ២-៣ អាទិត្យបន្ទាប់ពីកូនដុះហើយ



## ការថែទាំ

- ត្រូវដាក់ទ្រើងភ្លាមបន្ទាប់ពីដាំគ្រាប់ហើយ មិនត្រូវអោយយឺតជាង៧ថ្ងៃទេ បើដាក់ទ្រើងយឺតធ្វើអោយសណ្ដែកមិនល្អ



- កុំធ្វើទ្រើងខ្ពស់ពេក នាំអោយគ្រោះថ្នាក់ពេលបាញ់ថ្នាំពុល
- ត្រូវស្រោចទឹកអោយបានគ្រប់គ្រាន់នៅពេលព្រឹក ជៀសវាងស្រោចទឹកច្រើនពេកធ្វើឲ្យដីសើមជ្រុល នៅពេលថ្ងៃល្ងាចវាអាចបង្កអោយមានបញ្ហាដល់ដំណាំបានធ្វើស្មៅឲ្យបានញឹកញាប់តែជៀសវាងធ្វើស្មៅពេញដីនៅសើមជោគជាំ ។



ការប្រើប្រាស់ជី ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន )

| ពេលវេលា | ប្រភេទជីប្រើក្នុងចន្លោះគុម្ពទាំងបួន | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| មុនដាំគ្រាប់ | ជីលាមកសត្វស្ងួត ០.៥ គីឡូក្រាម ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយ (៥ក្រាម) | ពង្រាយលើរងហើយកាប់ច្របល់និងដី |
| ៣ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជីអ៊ុយរ៉េ  កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីពក់ៗ ចំងាយពីគល់កន្លះតឹក |
| ៥ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីពក់ៗ ចំងាយពីគល់១តឹក |
| | ចាប់ផ្ដើមប្រមូលផល | |
| ៧ អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥)កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីពក់ៗ ចំងាយពីគល់ ១តឹកកន្លះ |
| ១០អាទិត្យបន្ទាប់ពីដាំគ្រាប់ | ជី អិន ប៉េ កា (១៥. ១៥.១៥) កន្លះស្លាបព្រាបាយស្មើ (៥ក្រាម) | កប់ជីពក់ៗ ចំងាយពីគល់១តឹកកន្លះ |
| ១៤ អាទិត្យបន្ទាប់ពីដាំ | បញ្ចប់ការប្រមូលផល | |